# មេរៀនទី៣៣៖ មនុស្សសាងសង់ប៉មនៅក្រុងបាបិល

## លោកុប្បត្តិ ១១៖១-៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/SUdyb1rw-O8

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/sSnVmquDkqo

**គោលបំណង៖** ព្រះគឺជាគ្រប់យ៉ាងដែលយើងត្រូវការ។

**ខគម្ពីរចងចាំ៖ ភីលីព៤៖១៩** *"ព្រះនៃខ្ញុំ ទ្រង់នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការតាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូវ។"*

**ចំរៀង** ( *យូធូបលីង* )៖

១.ចូរយើងស្រែកច្រៀងសរសើរព្រះអង្គ https://youtu.be/gunBpYl_uog

២.មួយ ពីរ ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/32BRXvDba4w

៣.ព្រះទតមើលក្នុងចិត្ត https://youtu.be/MRNo_yoVxno

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «តោះរៀនភាសាអេស្ប៉ាញ»




១. ឲ្យកុមារឈរទាំងអស់គ្នានៅកណ្តាលថ្នាក់រៀន សូមពន្យល់កុមារថា នៅពេលដែលគ្រូនិយាយលេខ ណាមួយពី ១-៥ នោះកុមារត្រូវរត់រកគ្នាឲ្យបានតាមចំនួនលេខដែលគ្រូហៅ។




២. សូមពន្យល់កុមារថា គ្រូនឹងនិយាយលេខនោះជាភាសាអេស្ប៉ាញ ជំនួសឲ្យការនិយាយជាភាសាខ្មែរ ដូច្នេះកុមារត្រូវទាយតាមលេខទាំងនោះ៖

ក. មួយ - uno (អ៊ូណូ)　　ខ. ពីរ - dos (ដ៉ឹស)

គ. បី - tres( ត្រេស )　ឃ.　បួន - quatro (ខ្វាត្រូ)　　ង. ប្រាំ - cinco( ស៊ីនកូ )

៣. សូមកុំប្រាប់កុមារថាវាជាលេខប៉ុន្មាន ប៉ុន្តែគ្រូគ្រាន់តែទុកអ្នកដែលទាយត្រូវ ដើម្បីលេងល្បែងនេះបន្ត។ បន្តលេងល្បែងនេះរហូតនៅសល់កុមារតិចជាង ៣នាក់ជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមសួរកុមារថា តើពួកគេមានអារម្មណ៍ដូចម្តេច នៅពេលដែលគេមិនយល់ពីភាសានោះ។ បន្ទាប់មកសូមពន្យល់កុមារថា កាលពីយូរលង់ណាស់មកហើយមនុស្សគឺនិយាយភាសាដូចៗគ្នា ហើយថ្ងៃនេះយើងនឹងរៀនថា ហេតុអ្វីបានជាមានភាសាខុសគ្នាទៅវិញ។

### ៤. ការណែនាំមេរៀន

តើមានអ្វីខ្លះដែលអាចរក្សាយើងឲ្យមានជីវិតបាន? ម្ហូបអាហារ? ទឹក?ខោអាវ? ផ្ទះ? មានរបស់ជាច្រើនដែលយើងត្រូវការ ហើយមានរឿងជាច្រើនដែលមានសារៈសំខាន់សម្រាប់ពួកយើង។ ប៉ុន្តែថ្ងៃនេះ យើងនឹងរៀនថា របស់ដែលចាំបាច់បំផុតសម្រាប់ជីវិតយើងនោះ គឺជាព្រះ ពីព្រោះថាគ្រប់របស់ទាំងអស់គឺបានមកពីព្រះ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះបានប្រាប់យើងអំពីរឿងរ៉ាវ ដែលបានកើតឡើងប្រហែលកាលពី ១៥០ឆ្នាំទៅ ២០០ឆ្នាំមុន បន្ទាប់ពីសាច់រឿងរបស់លោកណូអេ។ ព្រះចង់ឲ្យមនុស្សគ្រប់គ្នាដឹងថា ពួកគេត្រូវការព្រះ ពីព្រោះថាគ្រប់យ៉ាងគឺបានមកពីព្រះ។ ព្រះអង្គចង់ឲ្យមនុស្សទាំងអស់ទុកចិត្ត និងមានសេចក្តីជំនឿលើទ្រង់។ បើទោះបីជាយ៉ាងនេះក្តី ពេលវេលាចេះតែរំកិលទៅមុខ មនុស្សក៏ចាប់ផ្តើមមិនខ្វល់ខ្វាយក្នុងការសរសើរតម្កើង និងស្តាប់បង្គាប់ព្រះ។ ពួកគេបានភ្លេចថា ព្រះគឺជាគ្រប់យ៉ាងដែលពួកគេត្រូវការ។ ពួកគេបានសម្រេចចិត្តថា ជំនួសឲ្យការដែលទុកចិត្តព្រះ ពួកគេនឹងធ្វើឲ្យខ្លួនគេបានល្បី។

មនុស្សមួយចំនួនដែលរស់នៅបាបិល បានសម្រេចចិត្តសាងសង់ប៉មមួយ ដើម្បីបង្ហាញថាពួកគេមានសារៈសំខាន់ និងធ្វើបានល្អប៉ុនណា។ ពួកគេក៏ចាប់ផ្តើមធ្វើឥដ្ឋ ហើយចាប់ផ្តើមសាងសង់ប៉មដ៏ខ្ពស់មួយ។ ពួកគេបានគិតថាពួកគេខ្លាំង និងមានសារៈសំខាន់។

ព្រះបានទតឃើញពីអ្វីដែលមនុស្សបានសាងសង់នៅបាបិល។ ព្រះបានជ្រាបដឹងថា ប្រសិនបើទ្រង់បណ្តោយឲ្យមនុស្សសាងសង់ប៉មនោះ ពួកគេច្បាស់ជាគិតថា ពួកគេគឺអាចពឹងផ្អែកលើខ្លួនបាន ជំនួសឲ្យការដែលពឹងផ្អែកលើព្រះ។ ព្រះជាម្ចាស់ស្រលាញ់មនុស្សខ្លាំងណាស់។ ព្រះអង្គមិនចង់ឲ្យមនុស្សភ្លេចទ្រង់នោះទេ ដូច្នេះព្រះក៏បានសម្រេចចិត្តបញ្ឈប់ពួកគេពីការសាងសង់ប៉មនោះ។

នៅពេលនោះមនុស្សគ្រប់គ្នាគឺនិយាយភាសាដូចគ្នា។ មនុស្សទាំងអស់នៅឯបាបិលគឺអាចយល់និង ស្តាប់គ្នាបាន។ ដូច្នេះព្រះបានផ្លាស់ប្តូរភាសាមនុស្សទាំងអស់។ នៅពេលដែលមនុស្សនៅក្នុងសាច់រឿងចាប់និយាយភាសាខុសគ្នា ពួកគេក៏ស្តាប់គ្នានិយាយ មិនយល់ទៀតនោះទេ។ នៅពេលដែលពួកគេនិយាយគ្នាស្តាប់មិនយល់ ពួកគេគឺត្រូវតែបញ្ឈប់ការសាង សង់ប៉មនោះ។ ហើយនៅពេលដែលមនុស្សនិយាយស្តាប់គ្នាមិនយល់ គេក៏ចាប់ផ្តើមមានការភ័យខ្លាច។

នៅទីបំផុតពួកគេក៏បានដឹងថា ពួកគេគ្មានអំណាចអ្វីសោះ ហើយព្រះគឺពេញដោយអំណាចព្រះចេស្តា។ មនុស្សនៅក្នុងក្រុងបាបិលបានរកឃើញថា ពួកគេគួរតែពឹងផ្អែកលើព្រះជាជាងពឹងអាងលើខ្លួនឯង។ ពួកគេមិនត្រូវការប៉មដ៏ខ្ពស់នោះទេ។ អ្វីដែលពួកគេត្រូវការបំផុតនោះគឺព្រះ។ ហើយព្រះគឺជាអ្វី ដែលយើងត្រូវការបំផុតផងដែរ។ ទ្រង់បានផ្តល់នូវអ្វីគ្រប់យ៉ាងដែលយើងត្រូវការ។ តោះសូមឲ្យយើងបានអរព្រះគុណដល់ព្រះ ដែលទ្រង់បានផ្តល់នូវអ្វីគ្រប់យ៉ាងដែលយើងត្រូវការ។

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាមនុស្សនៅបាបិលចង់សាងសង់ប៉មដ៏ខ្ពស់មួយ?
*(ពួកគេបានភ្លេចព្រះគឺជាអ្វីដែលពួកគេត្រូវការបំផុត ដើម្បីធ្វើឲ្យពួកគេល្បីនិងមានសារៈសំខាន់)*
២. ហេតុអ្វីបានជាព្រះបញ្ឈប់ពួកគេពីការសាងសង់ប៉មនោះ?
*(ព្រះចង់រំលឹកពួកគេថាទ្រង់គឺជាគ្រប់យ៉ាងដែលពួកគេត្រូវការ)*
៣. តើព្រះបានបញ្ឈប់ពួកគេពីការសាងសង់ប៉មដោយរបៀបណា?
*(ព្រះបានធ្វើឲ្យមនុស្សគ្រប់គ្នានិយាយភាសាខុសៗគ្នា)*
៤. តើអ្វីមួយដែលយើងទាំងអស់គ្នាត្រូវការក្នុងជីវិត? *(យើងត្រូវការព្រះ)*

## ៧. ល្បែងកំសាន្ត "សាងសង់ប៉មដ៏ខ្ពស់មួយ"



សម្ភារៈដែលត្រូវការ៖ ក្រដាស(អាចកាត់ជាបំណែកតូចៗបាន)

១. ចែកកុមារជា៤-៥ ក្រុម ហើយឲ្យក្រដាស ១៥ សន្លឹកទៅក្រុមនីមួយៗ



២. ប្រាប់ឲ្យកុមារធ្វើប៉មពីក្រដាសឲ្យបាន ៤ ទៅ ៥ជាន់ ដោយប្រើក្រដាសបត់ជា២ជាគ្រឹះ និងដាក់ក្រដាសមួយសន្លឹកនៅពីលើ។
៣. ក្រុមណាដែលអាចធ្វើរួចមុនជាអ្នកឈ្នះ តែពួកគេត្រូវរងចាំក្រុមផ្សេងទៀតធ្វើឲ្យបាន ៤ ទៅ ៥ ជាន់សិន។
៤. បន្ទាប់ពីក្រុមទាំងអស់ធ្វើរួច សូមពន្យល់ទៅកុមារថា មនុស្សគិតថាពួកគេអាចធ្វើកិច្ចការទាំងអស់បានដោយខ្លួនឯង ប៉ុន្តែគ្រប់របស់ទាំងអស់ដែលយើងបង្កើតនោះគឺគ្មានអំណាចអ្វីទាំងអស់។
៥. ឲ្យកុមារផ្តំប៉មរបស់ពួកគេឲ្យដួល។
៦. សូមពន្យល់កុមារថា បើគ្មានការជួយពីព្រះ នោះរបស់គ្រប់យ៉ាងដែលយើងបង្កើតគឺត្រឡប់ជាគ្មានន័យអ្វីទាំងអស់។ យើងមិនអាចធ្វើអ្វីទាំងអស់បើគ្មានការជួយដែលបានមកពីព្រះ។ ព្រះគឺជាគ្រប់យ៉ាងដែល យើងត្រូវការ។

## ៨. ខគម្ពីរចងចាំ

**ភីលីព៤:១៩** *"ព្រះនៃខ្ញុំ ទ្រង់នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការ តាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូវ។"*

**៩. ហត្ថកម្ម** ជាត់ពណ៌ **"ប៉មនៃទីក្រុងបាបិល - ព្រះគឺជាគ្រប់យ៉ាងដែលយើងត្រូវការ"**
សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម និងកូល័រ
១. ឲ្យក្រដាសហត្ថកម្មទៅកុមារម្នាក់មួយសន្លឹក ហើយឲ្យពួកគេគូររូបប៉មដែលពួកគេគិតថាប៉មបាបិលមានរាងដូចម្តេច
២. ឲ្យកុមារផាត់ពណ៌រូបប៉មបាបិលនោះ ហើយសរសេរនូវខគម្ពីរចងចាំ។

**១០. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
គ្រប់ទាំងការសម្រេចចិត្ត និងបទពិសោធន៍ យើងត្រូវការព្រះជួយ។ ព្រះបានបំពេញសេចក្តីត្រូវការរបស់យើង តាមរយៈព្រះយេស៊ូវ គឺជាអ្នកដែលបានដែលបំពេញសេចក្តីត្រូវការដ៏ធំបំផុតរបស់យើងនូវសេចក្តីមេត្តាករុណា សេចក្តីស្រលាញ់ និងជីវិតអស់កល្ប។ តើអ្នកអាចពឹងផ្អែកលើព្រះបានដោយរបៀបណា? អនុញ្ញាតឲ្យអ្នកផ្សេងទៀតបានមើលឃើញពីការដែលអ្នកពឹងផ្អែកលើព្រះ។ បង្ហាញទៅកាន់អ្នកដទៃពីការដែលព្រះជួយអ្នក គឺជាទីបន្ទាល់ដ៏អស្ចារ្យសម្រាប់អ្នកដែលកំពុងមានការតស៊ូ។ សូមពិចារណាពីរបៀបដែលអ្នកអាចប្រើប្រាស់ជីវិតរបស់អ្នក ដើម្បីបង្ហាញទៅកាន់សិស្សរបស់អ្នកថា ព្រះតែងតែមើលថែពួកគេជានិច្ច។

# ប៉មនៃទីក្រុងបាបិល - ព្រះគឺជាគ្រប់យ៉ាងដែលយើងត្រូវការ

គូររូបប៉មនៃទីក្រុងបាបិល

សូមសរសេរខគម្ពីរចងចាំ:________________________________

______________________________________________

______________________________________________